ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០០៦.....សហវ.អឌក

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ២០១២

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបលោក-លោកស្រី ដែលជាម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ មេត្តាជ្រាបថា ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១២ ត្រូវចាប់អនុវត្តពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ រហូតដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២ ។

ពន្ធនេះត្រូវបានលើកលែងចំពោះ ៖

-រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គីភ័យរបស់រដ្ឋ

-មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ជាកម្មសិទ្ធិរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបំរើឱ្យការងារសម្រាប់កិច្ចការពារប្រទេស សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម

-មធ្យោបាយដឹកជញ្ជូន និងយានជំនិះរបស់បេសកកម្មទូត ឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។

ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១២ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវបំពេញនូវលិខិតប្រកាសចំនួន ០២ សន្លឹក តាមគំរូឯកភាពរបស់អគ្គនាយកដ្ឋានពន្ធដារ (លើកលែងតែម្ចាស់ទោចក្រយានយន្ត និងត្រីចក្រយានយន្តបំពាក់ដោយម៉ាស៊ីនម៉ូតូ) ព្រមទាំងត្រូវបង្ហាញ និងប្រគល់ជូនមន្ត្រីដែលមានសមត្ថកិច្ចនូវបង្កាន់ដៃបង់ពន្ធសម្រាប់ឆ្នាំ២០១១ សម្រាប់ជាភស្តុតាងបញ្ជាក់ថា មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះបានបង់ពន្ធសម្រាប់ឆ្នាំ២០១១រួចហើយ ។ ក្នុងករណីបាត់បង្កាន់ដៃបង់ពន្ធសម្រាប់ឆ្នាំ២០១១ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ត្រូវមានលិខិតបញ្ជាក់ថាបានបង់ពន្ធសម្រាប់ឆ្នាំ២០១១ ដែលចេញដោយប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ នៃទីកន្លែងដែលយានយន្តនោះបានបង់ពន្ធសម្រាប់ឆ្នាំ២០១១ ។

ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះទាំងឡាយណាដែលពុំមានបង្កាន់ដៃបង់ពន្ធឆ្នាំ២០១១ទេនោះ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះ ត្រូវបង់ពន្ធសម្រាប់ឆ្នាំ២០១១ និងត្រូវបង់ប្រាក់ពិន័យដែលមានចំនួនស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92 Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone 855-23-724 664 Fax 855-23-427 798
mef_adm@yahoo.com

ប្រភេទសម្រាប់ឆ្នាំ២០១២ ។ លើកលែងតែទោចក្រយានយន្ត និងត្រីចក្រយានយន្តបំពាក់ដោយម៉ាស៊ីនម៉ូតូប៉ុណ្ណោះ ដែលពុំចាំបាច់ឱ្យម្ចាស់បង្ហាញបង្កាន់ដៃបង់ពន្ធឡើយ គឺគ្រាន់តែទិញបណ្ណបង់ពន្ធយកទៅបិទយានយន្តរបស់ខ្លួនជាការស្រេច ។ ក្នុងករណីទោចក្រយានយន្ត និងត្រីចក្រយានយន្តណាមួយគ្មានបិទបណ្ណបង់ពន្ធ ត្រូវចាត់ទុកថាមិនទាន់បានបង់ពន្ធនៅឡើយ ។

ក្រោយពេលបង់ពន្ធបានត្រឹមត្រូវរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗ ត្រូវបានទទួលបង្កាន់ដៃបង់ពន្ធមួយសន្លឹក និងបណ្ណបង់ពន្ធមួយសន្លឹកសម្រាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗ នោះ ។ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវរក្សាទុកបង្កាន់ដៃបង់ពន្ធ និងត្រូវយកជាប់ជាមួយសម្រាប់ទុកបង្ហាញ មន្ត្រីត្រួតពិនិត្យដែលមានសមត្ថកិច្ច ។

ចំពោះមធ្យោបាយដឹកជញ្ជូនដែលជាទ្រព្យសកម្មរបស់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវមកបំពេញលិខិតប្រកាសតាមគំរូដោយឡែក និងបង់ពន្ធនៅអង្គភាពពន្ធដារដែលសហគ្រាសបានប្រកាសបង់ពន្ធ-អាករ ជារៀងរាល់ខែនោះ ។

ការត្រួតពិនិត្យការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១២ ត្រូវអនុវត្ត ចាប់ពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២ តទៅ ។

ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលទើបដាក់ឱ្យធ្វើចរាចរនៅក្រោយថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២ ត្រូវមានវិក្កយបត្រ ឬឯកសារផ្សេងៗ ចេញដោយអ្នកលក់ អមដោយបង្កាន់ដៃបង់ពន្ធនាំចូល ឬបណ្ណសំគាល់យានយន្ត (ចតចម្លង) ភ្ជាប់ជាមួយលិខិតប្រកាសសុំបង់ពន្ធ និងត្រូវមកប្រកាសបង់ពន្ធនៅតាមទីស្នាក់ការពន្ធដារ ឬទីកន្លែងប្រមូលពន្ធដែលកំណត់ដោយសាខាពន្ធដារខេត្ត-ខណ្ឌ នៅរៀងរាល់ថ្ងៃធ្វើការ ។ បើពុំមកប្រកាសសុំបង់ពន្ធក្នុងរយៈពេល ១ខែ គិតពីថ្ងៃដែលដាក់ឱ្យធ្វើចរាចរ ត្រូវពិន័យចំនួនមួយដងស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់សម្រាប់ ឆ្នាំ២០១២នេះ ។

សម្រាប់ឆ្នាំ២០១២នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផលិតបណ្ណ លតាបត្រពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដោយមានគុណភាព មានសញ្ញាចំណាំ និងលេខកូដ ដែលអាចផ្ទៀងផ្ទាត់ ឬប្រើប្រាស់ឧបករណ៍ស្វ័យប្រវត្តិ ដើម្បីត្រួតពិនិត្យលក្ខណៈពិតប្រាកដ និងក្លែងក្លាយរបស់លតាបត្រទាំងនោះ ។ ដូច្នេះដើម្បីជៀសវាង ការទិញបណ្ណបង់ពន្ធក្លែងក្លាយនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមអញ្ជើញ លោក-លោកស្រី ជាម្ចាស់យានយន្តទៅ ប្រកាសបង់ពន្ធដោយផ្ទាល់នៅតាមទីកន្លែងប្រមូលពន្ធដែលកំណត់ដោយសាខាពន្ធដារខេត្ត-ខណ្ឌ ដែលនៅជិតគេហដ្ឋាន លោក-លោកស្រី ។

អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជូនដំណឹងដល់ម្ចាស់យានយន្តគ្រប់ប្រភេទមេត្តារួសរាន់អញ្ជើញទៅបង់ពន្ធនេះឱ្យបានមុនថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២ កុំបីខាន ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់